PARLIAMENTARY CENTRE OF ASIA
Strengthening Parliamentary Capacity

# ឯកសារស្រាវជ្រាវសង្ខេប

## គណៈកម្មការទី៨នៃរដ្ឋសភា
## សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន
## យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី

# ការវិភាគអំពីចំណាយសុខភាពសាធារណៈ និងផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃជំងឺមិនឆ្លង នៅក្នុងប្រទេសកម្ពុជា

ខែមិនា ឆ្នាំ២០២៣

លោក អ៊ឹង ខ្វាន់ថៃ អ្នកស្រាវជ្រាវ CDRI

# កំណត់សម្គាល់

មជ្ឈមណ្ឌលសភាអាស៊ី (ម.ស.អ) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភា ទាំងឡាយតាមការស្នើសុំរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញសភា និងអគ្គលេខាធិការដ្ឋាន តាមរយៈការផ្តល់ជូននូវការបណ្តុះបណ្តាល និងការស្រាវជ្រាវជាច្រើន ស្តីពីបញ្ហាសំខាន់ៗដែលកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់មជ្ឈមណ្ឌលសភាអាស៊ី សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាឱ្យបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីមជ្ឈមណ្ឌល។

រក្សាសិទ្ធិ ឆ្នាំ២០២៣ មជ្ឈមណ្ឌលសភាអាស៊ី (ម.ស.អ)។

# មាតិកា


សារសំខាន់ៗ ........ 1

សេចក្តីផ្តើម ........ 2

វិធីសាស្ត្រស្រាវជ្រាវ ........ 2

លទ្ធផលរកឃើញ ........ 3

១. ការចំណាយលើកម្មវិធីសុខភាពសម្រាប់ជំងឺឆ្លង និងជំងឺមិនឆ្លង ........ 3

២. បន្ទុកហិរញ្ញវត្ថុនៃជំងឺមិនឆ្លង ទៅលើវិស័យសុខភាពសាធារណៈ និងកំណើនសេដ្ឋកិច្ច ........ 5

៣. ផលប៉ះពាល់ពីជំងឺមិនឆ្លងលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាជន ........ 8

ការពិភាក្សាលើលទ្ធផលរកឃើញ ........ 10

សេចក្តីសន្និដ្ឋាន ........ 11

## សារសំខាន់ៗ

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការព្យាបាលនិងការកៀរគរធនធាន សម្រាប់ការប្រយុទ្ធនឹងជំងឺមិនឆ្លង ការសិក្សាសូមផ្តល់យោបល់ចំនួនបួនសំខាន់ៗដូចខាងក្រោម៖

១. **ពិនិត្យឡើងវិញចំពោះការបែងចែកថវិកាលើកម្មវិធីជំងឺមិនឆ្លងក្នុងវិស័យសុខភាពសាធារណៈ៖** ពិចារណាបង្កើនថវិកាសម្រាប់កម្មវិធីជំងឺមិនឆ្លង ជាពិសេសជំងឺពុំរ៉ៃ ដូចជាជំងឺទឹកនោមផ្អែម ជំងឺក្រពះ ពោះវៀន/រលាកក្រពះ ជំងឺបេះដូង ជំងឺទឹកនោមផ្អែម ជំងឺឈឺចាប់សន្លាក់ និងជំងឺមិនឆ្លងផ្សេងទៀត។ ការបង្កើនថវិកា អាចបានពីការបែងចែកកញ្ចប់ថវិកាឡើងវិញចេញពីកម្មវិធីទី៤ស្តីពីការពង្រឹងប្រព័ន្ធសុខាភិបាល និងការរួមបញ្ចូលសេវាសុខភាពជំងឺមិនឆ្លង ទៅក្នុងកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍នៃថវិកាសុខភាពសាធារណៈ។

២. **តម្លើងពន្ធលើផលិផលដែលប៉ះពាល់សុខភាព៖** ស្នើយកពន្ធលើផលិតផលដែលបង្កគ្រោះថ្នាក់ដល់សុខភាព និងតម្លើងពន្ធលើថ្នាំជក់ គ្រឿងស្រវឹង និងភេសជ្ជៈផ្អែមដែលមានជាតិស្ករខ្ពស់ ហើយប្រើប្រាស់ប្រាក់ចំណូលមួយផ្នែកពីពន្ធនេះ សម្រាប់ការបង្ការ និងការគ្រប់គ្រងជំងឺមិនឆ្លង។

៣. **លើកកម្ពស់ការយល់ដឹងអំពីការបង្ការ និងការព្យាបាលជំងឺមិនឆ្លងនៅថ្នាក់ក្រោមជាតិ៖** បញ្ចូល និងសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញការបង្ការ និងការព្យាបាលជំងឺមិនឆ្លងដល់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ។ លើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នានានៃជំងឺមិនឆ្លង និងអត្ថប្រយោជន៍នៃការអនុវត្តសុខុមាលភាពដល់ប្រជាជន។ ការកៀរគរធនធានសម្រាប់ការងារនេះ គួរពិនិត្យមើលថវិកាថ្នាក់ក្រោមជាតិ និងការគាំទ្រពីភាគីពាក់ព័ន្ធ។

៤. **ដោះស្រាយជំងឺមិនឆ្លងតាមរយៈ ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន (PPP)៖** តួនាទី និងទំនួលខុសត្រូវរបស់ភាគីក្នុង PPP ចាំបាច់ត្រូវកំណត់ឱ្យបានល្អិតល្អន់។ លើសពីនេះយុទ្ធសាស្ត្រទំនាក់ទំនង និងការកសាងទំនុកចិត្តក្នុងចំណោមភាគីពាក់ព័ន្ធ ត្រូវធ្វើឡើងដោយផ្អែកលើកិច្ចព្រមព្រៀងជាក់លាក់។ ជាចុងក្រោយ ការរៀបចំផែនការ និងការអនុវត្តកម្មវិធីជំងឺមិនឆ្លង ចាំបាច់ត្រូវត្រួតពិនិត្យ និងវាយតម្លៃឱ្យបានត្រឹមត្រូវ។

## សេចក្តីផ្តើម

គណៈកម្មការទី៨នៃរដ្ឋសភា បានប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាជំងឺមិនឆ្លង ដោយត្រួតពិនិត្យលើការចំណាយរបស់រដ្ឋាភិបាល និងការអនុវត្តច្បាប់ថវិកា ដើម្បីធានាឱ្យមានគណនេយ្យភាពក្នុងការចំណាយសាធារណៈ។ ស្របតាមគោលបំណងនេះ ការសិក្សាបានវិភាគចំណាយសុខភាពសាធារណៈ ផលប៉ះពាល់សេដ្ឋកិច្ចសង្គម និងគូសវាសធនធាន ដើម្បីដោះស្រាយហានិភ័យនៃជំងឺមិនឆ្លងនៅកម្ពុជា។ ការសិក្សាបានលើកឡើងនូវគោលបំណងស្រាវជ្រាវសំខាន់ៗចំនួនបី៖

១. វែកញែកលំនាំការចំណាយសុខភាពសាធារណៈទៅលើជំងឺឆ្លង និងជំងឺមិនឆ្លង ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ (២០១៨-២០២២) នៃទិន្នន័យចំណាយរបស់រដ្ឋាភិបាល ហើយបែងចែកខ្ទង់ចំណាយសំខាន់ៗ នៅថ្នាក់ជាតិ ថ្នាក់កម្មវិធី និងអនុកម្មវិធី។

២. ពិនិត្យមើលបន្ទុកហិរញ្ញវត្ថុរបស់ជំងឺមិនឆ្លង ទៅលើវិស័យសុខភាពសាធារណៈ និងកំណើនសេដ្ឋកិច្ច។

៣. ប៉ាន់ប្រមាណផលប៉ះពាល់ពីជំងឺមិនឆ្លង ទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាជន និងកំណត់ធនធានដែលមានសក្តានុពល ដើម្បីដោះស្រាយហានិភ័យនៃជំងឺមិនឆ្លង ដោយពិចារណាលក្ខខណ្ឌយេនឌ័រ។

## វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានប្រើវិធីសាស្ត្រប្រមូលទិន្នន័យជាប្រព័ន្ធ ដោយរួមបញ្ចូលរបាយការណ៍បច្ចេកទេស និងឯកសារយុទ្ធសាស្ត្រដែលមានស្រាប់។ ដំណើរការប្រមូលទិន្នន័យនេះ ធានាបាននូវគុណភាពទិន្នន័យ និងកែលំអសុពលភាពនៃការសិក្សាវិភាគ។ ដូច្នេះហើយ ការស្រាវជ្រាវបានប្រមូលសំណុំទិន្នន័យពីផែនការថវិកាជាតិសម្រាប់ឆ្នាំ២០១៨-២០២២ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MoEF) និងឯកសារពីក្រសួងសុខាភិបាល (MoH) វិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ (MoP) ក្រុមធនាគារពិភពលោក និងអង្គការសុខភាពពិភពលោក (WHO)។ ចុងក្រោយ ការសិក្សាបានប្រើទិន្នន័យពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ (CSES 2020) ដើម្បីប៉ាន់ប្រមាណពីផលប៉ះពាល់ជំងឺមិនឆ្លង ទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាជន (NIS, 2020)។

ការសិក្សាបានប្រើវិធីសាស្ត្របរិមាណវិស័យ ដើម្បីវិភាគការចំណាយសុខភាពសាធារណៈ និងផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃជំងឺមិនឆ្លងនៅកម្ពុជា។ ការវិភាគបានដំណើរការជាបីកម្រិត៖ កម្រិតជាតិ កម្រិតកម្មវិធី និងកម្រិតគ្រួសារ។ ការសិក្សាបានប្រើស្ថិតិពិពណ៌នា ដើម្បីកំណត់លក្ខណៈនៃការចំណាយសុខភាពសាធារណៈ ដោយបង្កើតសេចក្តីសង្ខេប និន្នាការ និងរង្វាស់ប្រៀបធៀប។

ការសិក្សាបានប្រើការវិភាគ Two-way ANOVA (វិភាគលើការប្រែប្រួល និងការធ្វើតេស្តរកភាពខុសគ្នានៃឥទ្ធិពលអថេរឯករាជ្យ លើអថេរអាស្រ័យ) ដើម្បីធ្វើតេស្តរកភាពខុសគ្នា ចំពោះបន្ទុកហិរញ្ញវត្ថុនៃថ្លៃព្យាបាលជំងឺមិនឆ្លង គិតជាដុល្លារ (USD) លើលក្ខខណ្ឌយេនឌ័រ និងគ្រួសារមកពីតំបន់ទាំងប្រាំ[1] រួមមាន តំបន់

---

[1]
- តំបន់ភ្នំពេញ៖ រាជធានីភ្នំពេញ។
- តំបន់វាលទំនាប៖ ខេត្តកំពង់ចាម ត្បូងឃ្មុំ កណ្ដាល ព្រៃវែង ស្វាយរៀង និងតាកែវ។
- តំបន់ទន្លេសាប៖ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន។
- តំបន់ឆ្នេរ៖ ខេត្តកំពត កោះកុង ព្រះសីហនុ និងកែប។

ភ្នំពេញ តំបន់វាលទំនាប តំបន់ទន្លេសាប តំបន់ឆ្នេរ និងតំបន់ភ្នំ។ ជាចុងក្រោយ ការសិក្សាបានប្រើការវិភាគ Multiple regression ដើម្បីពិនិត្យមើលទំនាក់ទំនងរវាងថ្លៃព្យាបាលជំងឺមិនឆ្លងគិតជាដុល្លារ (USD) និងលក្ខណៈសេដ្ឋកិច្ចសង្គម និងការអនុវត្តសុខុមាលភាពរបស់គ្រួសារ។

## លទ្ធផលរកឃើញ

### ១. ការចំណាយលើកម្មវិធីសុខភាពសម្រាប់ជំងឺឆ្លង និងជំងឺមិនឆ្លង

យោងតាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការចំណាយលើវិស័យសុខភាពសាធារណៈនៅប្រទេសកម្ពុជាត្រូវបានបែងចែកទៅបួនកម្មវិធី៖ ១. សុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ ២. ប្រយុទ្ធនឹងជំងឺឆ្លង ៣. ប្រយុទ្ធនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត និង ៤. ពង្រឹងប្រព័ន្ធសុខាភិបាល។ គេសង្កេតឃើញថា ថវិកាសរុបសម្រាប់កម្មវិធីរបស់ក្រសួងសុខាភិបាលបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ពី ១.៥៤៥.៥២៥លានរៀលក្នុងឆ្នាំ២០១៩ ស្មើនឹងអត្រាកំណើនប្រចាំឆ្នាំ ១១% ចុះមកត្រឹម ១.៣៤១.៣៧៧ លានរៀល ក្នុងឆ្នាំ២០២២ ឬស្មើនឹងការថយចុះ ២២% នៃអត្រាកំណើនប្រចាំឆ្នាំ[2]។

លទ្ធផលវិភាគ (តារាង១) បង្ហាញថា ថវិកាក្នុងកម្មវិធីទី៤ មានច្រើនជាង ៩០% នៃថវិកាសុខភាពសាធារណៈសរុបក្នុងរយៈពេល ប្រាំឆ្នាំចុងក្រោយនេះ ហើយបានបែងចែកទៅអនុកម្មវិធី៖ ១. ការផ្តល់សេវាសុខាភិបាល ២. ហិរញ្ញប្បទានសុខាភិបាល ៣. អភិវឌ្ឍធនធានមនុស្ស ៤. ប្រព័ន្ធព័ត៌មានសុខាភិបាល ៥. អភិបាលកិច្ចវិស័យសុខាភិបាល និង ៦. សេវាគាំទ្រពង្រឹងប្រព័ន្ធសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត។ ក្នុងចំណោមអនុកម្មវិធី ការផ្តល់សេវាសុខភាព បានប្រើប្រាស់ថវិកាច្រើនជាង ៨៨% នៃផែនការថវិកាសម្រាប់ឆ្នាំ២០២២។

*តារាង១៖ របាយថវិកាសុខភាពសាធារណៈ* *គិតជាលានរៀល*

| កម្មវិធី | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|
| កម្មវិធីទី១៖ សុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ | 95,924.8 | 116,612.8 | 117,723.5 | 117,082.7 | 110,138.9 |
| កម្មវិធីទី២៖ ប្រយុទ្ធនឹងជំងឺឆ្លង | 16,493.6 | 19,869.9 | 22,302.8 | 25,362 | 26,958.1 |
| កម្មវិធីទី៣៖ ប្រយុទ្ធនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត | 2,527.6 | 3,256.8 | 3,028.1 | 2,586.9 | 1,543.3 |
| កម្មវិធីទី៤៖ ពង្រឹងប្រព័ន្ធសុខាភិបាល | 1,279,028.1 | 1,405,785.5 | 1,493,443.6 | 1,575,652.4 | 1,202,736.7 |
| **ថវិកាសរុប** | 1,393,974.1 | 1,545,525 | 1,636,498 | 1,720,684 | 1,341,377 |
| **អត្រាកំណើន** | **ឆ្នាំមូលដ្ឋាន** | 0.11 | 0.06 | 0.05 | -0.22 |

ប្រភព៖ គណនាទិន្នន័យបានពី (MoEF, 2022)

ការបង្ការ និងថែទាំព្យាបាលជំងឺអេដស៍ និងជំងឺរបេង គឺជារបៀបវារៈអាទិភាពសម្រាប់កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង។ ការបង្ការ និងថែទាំព្យាបាលជំងឺអេដស៍ បានប្រើប្រាស់ថវិកាច្រើនជាង ៥០% នៃថវិកាសម្រាប់ប្រយុទ្ធ

- តំបន់ភ្នំ៖ ខេត្តកំពង់ស្ពឺ ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី និង ស្ទឹងត្រែង។

[2] កញ្ចប់ថវិកាសម្រាប់ឆ្នាំ២០២២ បានបែងចែកដើម្បីស្តារឡើងវិញ កសាងឡើងវិញ និងភាពធន់នៃសេដ្ឋកិច្ចសង្គម និងកំណើនពីជំងឺកូវីដ-១៩។

នឹងជំងឺឆ្លង ហើយការបង្ការ និងថៃទាំព្យាបាលជំងឺរបេងមានជាង ៣២% សម្រាប់រយៈពេលប្រាំឆ្នាំចុងក្រោយ (២០១៨-២០២២)។ យ៉ាងណាក៏ដោយ ការបង្ការ និងថៃទាំព្យាបាលជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម ព្រមទាំងជំងឺឆ្លងផ្សេងទៀត បានថយចុះពី ១២ ទៅ ៧% ក្នុងអំឡុងពេលដូចគ្នា។ សេវាគាំទ្រប្រយុទ្ធនឹងជំងឺឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានី-ខេត្ត បានថយចុះចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២១ ហើយមិនត្រូវបានបែងចែកថវិកានោះទេសម្រាប់ឆ្នាំ២០២២។ យោងតាមលទ្ធផលនេះ ថវិកាសម្រាប់ការបង្ការ និងថៃទាំព្យាបាលជំងឺអេដស៍និងជំងឺរបេងត្រូវបានបែងចែក ដើម្បីឆ្លើយតបនឹងហានិភ័យ ដែលបណ្តាលមកពីជំងឺទាំងពីរនេះនៅក្នុងវិស័យសុខភាពសាធារណៈ។ ការវិភាគអនុកម្មវិធីជំងឺឆ្លង មានបង្ហាញក្នុងតារាង២។

*តារាង២៖ ការបែកញែកចំណាយសម្រាប់ជំងឺឆ្លង (២០១៨-២០២២)* *គិតជាលានរៀល*

| ការបែកញែកចំណាយសម្រាប់ជំងឺឆ្លង | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|
| **កម្មវិធីទី២៖ ប្រយុទ្ធជំងឺឆ្លង** | 16493.6 | 19869.9 | 22302.8 | 25362 | 26958.1 |
| អនុកម្មវិធីទី១៖ ការបង្ការ និងថៃទាំព្យាបាលជំងឺអេដស៍ | 9,220.70 | 9,145.40 | 9,192.40 | 12,478.00 | 16,090.70 |
| អនុកម្មវិធីទី២៖ ការបង្ការ និងថៃទាំព្យាបាលជំងឺរបេង | 2,954.10 | 6,564.10 | 9,164.10 | 9,019.80 | 9,017.80 |
| អនុកម្មវិធីទី៣៖ ការបង្ការ និងថៃទាំព្យាបាលជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម | 1,252.10 | 1,256.90 | 1,256.90 | 1,228.90 | 1,228.90 |
| អនុកម្មវិធីទី៤៖ ការបង្ការ និងឆ្លើយតបជំងឺឆ្លងដទៃទៀត | 669.1 | 620.7 | 620.7 | 620.7 | 620.7 |
| អនុកម្មវិធីទី៥៖ សេវាគាំទ្រប្រយុទ្ធជំងឺឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានី ខេត្ត | 2,397.60 | 2,282.80 | 2,068.70 | 2,014.60 | អត់ថវិកា |
| អត្រាកំណើន | ឆ្នាំមូលដ្ឋាន | 20% | 12% | 14% | 6% |

ប្រភព៖ គណនាទិន្នន័យបានពី (MoEF, 2022)

ដូចបានបង្ហាញក្នុងតារាង៣ខាងក្រោម ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ សេវាគាំទ្រប្រយុទ្ធនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានីខេត្ត បានប្រើថវិកាភាគច្រើននៃកម្មវិធីប្រយុទ្ធនឹងជំងឺមិនឆ្លង។ ប៉ុន្តែសម្រាប់ឆ្នាំ២០២២ សេវាគាំទ្រប្រយុទ្ធនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានី-ខេត្ត មិនត្រូវបានទទួលថវិកានោះទេ។ នៅឆ្នាំ២០២២ បញ្ហាសុខភាពសាធារណៈផ្សេងៗទៀត បានប្រើប្រាស់ថវិកាអស់៥៣% នៃថវិកាសរុបសម្រាប់កម្មវិធីប្រយុទ្ធនឹងជំងឺមិនឆ្លង បន្ទាប់មកសុខភាពផ្លូវចិត្ត និងបំពានគ្រឿងញៀនប្រើថវិកាអស់ ៣១% សុខភាពមាត់ធ្មេញ ប្រើអស់ ៧% សុខភាពភ្នែកប្រើអស់ ៦% និងជំងឺរ៉ាំរ៉ៃ ប្រើអស់៣%។ ការធ្លាក់ចុះ ២២% នៃថវិកាសុខភាពសាធារណៈសរុប បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សេវាគាំទ្រប្រយុទ្ធនឹងជំងឺឆ្លង និងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានី-ខេត្ត។

*តារាង៣៖ ការបែកចែកចំណាយសម្រាប់ជំងឺមិនឆ្លង (២០១៨-២០២២)* *គិតជាលានរៀល*

| ការបែកចែកចំណាយសម្រាប់ជំងឺមិនឆ្លង | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|
| កម្មវិធីទី៣៖ ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត | 2527.6 | 3256.8 | 3028.1 | 2586.9 | 1543.3 |
| អនុកម្មវិធីទី១៖ សុខភាពភ្នែក | 110 | 100 | 100 | 100 | 100 |
| អនុកម្មវិធីទី២៖ សុខភាពផ្លូវចិត្ត និងបំពានគ្រឿងញៀន | 152 | 724.3 | 724.3 | 472.6 | 472.6 |
| អនុកម្មវិធីទី៣៖ សុខភាពមាត់ធ្មេញ | 104.6 | 107.3 | 107.3 | 107.3 | 107.3 |
| អនុកម្មវិធីទី៤៖ ជំងឺរ៉ាំរ៉ៃ | 112.2 | 67.3 | 67.3 | 59.6 | 51.9 |
| អនុកម្មវិធីទី៥៖ បញ្ហាសុខភាពសាធារណៈផ្សេងៗទៀត | 755.7 | 811.3 | 839.5 | 830.9 | 811.5 |
| អនុកម្មវិធីទី៦៖ សេវាគាំទ្រប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានីខេត្ត | 1,293.10 | 1,446.60 | 1,189.70 | 1,016.50 | អត់ថវិកា |
| អត្រាកំណើន | ឆ្នាំមូលដ្ឋាន | 29% | -7% | -15% | -40% |

ប្រភព៖ គណនាទិន្នន័យបានពី (MoEF, 2022)

## ២. បន្ទុកហិរញ្ញវត្ថុនៃជំងឺមិនឆ្លង ទៅលើវិស័យសុខភាពសាធារណៈ និងកំណើនសេដ្ឋកិច្ច

ការសិក្សារបស់UNDPនៅឆ្នាំ២០២០ ដែលបានវិភាគបន្ទុករបស់ជំងឺមិនឆ្លងទៅលើសុខភាពសាធារណៈ និងកំណើនសេដ្ឋកិច្ចបានរកឃើញថា ជំងឺមិនឆ្លងបានបង្កឱ្យមានបន្ទុកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរនៅថ្នាក់ជាតិ[3] ។ ការវិភាគបានរកឃើញបន្ទុកសេដ្ឋ-កិច្ច ដែលបណ្តាលមកពីជំងឺមិនឆ្លងនៅថ្នាក់ជាតិ ដែលមានចំនួន ៥,៩៧ ពាន់ពាន់លានរៀល (ឬ ១,៥ពាន់លានដុល្លារ) ស្មើនឹង ៦,៦% នៃផលិតផលក្នុងស្រុកសរុប (GDP)នៅឆ្នាំ២០១៧។ នេះបណ្តាលមកពីការចំណាយដោយប្រយោល ប្រហែល ៩៥% នៃបន្ទុកសេដ្ឋកិច្ចសរុប។ ការចំណាយដោយប្រយោល (រួមមាន អវត្តមានការងារ ការថយចុះសមត្ថភាពការងារ និងការស្លាប់មុនអាយុ) ស្មើនឹងទឹកប្រាក់ចំនួន ៥,៦៣ពាន់ពាន់លានរៀល (ឬ ១,៤ពាន់លានដុល្លារ) ដែលខ្ពស់ជាង ១៩ដង នៃការចំណាយដោយផ្ទាល់របស់រដ្ឋាភិបាល ដែលមានទឹកប្រាក់ចំនួន ៣៤៣ពាន់លានរៀល (ឬ ៨៤ លានដុល្លារ)។ ចុងក្រោយ ប្រជាជនកម្ពុជាដែលមានជំងឺមិនឆ្លង មួយក្នុងចំណោមជំងឺមិនឆ្លងទាំង៤ខាងក្រោម ទំនងជាស្លាប់មុនអាយុក្នុងអត្រា ២៣%[4]។

[3] UNDP. (2020). *Prevention and control of noncommunicable diseases in Cambodia | United Nations Development Programme*. Retrieved from https://www.undp.org/ cambodia/publications/prevention-and-control-noncommunicable-diseases-cambodia

[4] ស្លាប់មុនអាយុសំដៅលើការស្លាប់ក្រោមអាយុ៧០ឆ្នាំ

*តារាង៤៖ បន្ទុករបស់ជំងឺមិនឆ្លង* *គិតជាពាន់លានរៀល*

| ចំណាយ | ជំងឺបេះដូង | ជំងឺមហារីក | ជំងឺទឹកនោមផ្អែម | ជំងឺផ្លូវដង្ហើម | សរុប |
|---|---|---|---|---|---|
| **ចំណាយដោយផ្ទាល់** | | | | | |
| ចំណាយដោយផ្ទាល់របស់រដ្ឋាភិបាល | 154.00 | 77.00 | 46.00 | 67.00 | 343.00 |
| **ចំណាយដោយប្រយោល** | **656.00** | **4,266.00** | **628.00** | **76.00** | **5,626.00** |
| អវត្តមានការងារ | 17.00 | NA | 16.00 | NA | 33.00 |
| ការថយចុះសមត្ថភាពការងារ | 137.00 | NA | 529.00 | NA | 666.00 |
| ការស្លាប់មុនអាយុ | 503.00 | 4,266.00 | 83.00 | 76.00 | 4,928.00 |
| **បន្ទុកសេដ្ឋកិច្ចសរុប** | **810.00** | **4,343.00** | **674.00** | **143.00** | **5,970.00** |

ប្រភព៖ សង្ខេបពីទិន្នន័យ (UNDP, 2020)

កំណើនថវិកាសម្រាប់ប្រយុទ្ធនឹងជំងឺមិនឆ្លង ត្រូវបានប្រៀបធៀបជាមួយនឹងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (GDP សម្រាប់មនុស្សម្នាក់) ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ (រូបភាព១) (UNDP 2020)។ លទ្ធផលបានបង្ហាញពីស្ថិរ-ភាពនៃកំណើនផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ពី ១,៦៤៣ ដុល្លារក្នុងឆ្នាំ២០១៩ ដល់ ១,៧៨៥ដុល្លារក្នុងឆ្នាំ២០២២ ប៉ុន្តែថវិកាសម្រាប់ប្រយុទ្ធនឹងជំងឺមិនឆ្លងបានធ្លាក់ចុះពី ២៨% ក្នុងឆ្នាំ២០១៩ ដល់ ៤០% នៅឆ្នាំ២០២២[5]។ លើសពីនេះ ការចំណាយពីហោប៉ៅគិតជាភាគរយនៃការចំណាយថ្លៃព្យាបាលសរុបរបស់បុគ្គលម្នាក់ៗ (OOPS% CHE) នៅតែមានច្រើនជាង ៦០% នៃប្រភពថ្លៃព្យាបាលសរុបចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២០ (WHO, 2022)។ លទ្ធផលនេះបានបង្ហាញពីបន្ទុកហិរញ្ញវត្ថុកើនឡើងលើគ្រួសារ សម្រាប់ថ្លៃព្យាបាលជំងឺមិនឆ្លង ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ (២០១៩-២០២២)[6]។

លើសពីនេះ ក្រសួងសុខាភិបាលបានបញ្ជាក់នៅក្នុងផែនការសកម្មភាពពហុវិស័យជាតិសម្រាប់ការបង្ការ និងការប្រយុទ្ធនឹងជំងឺមិនឆ្លង (២០១៨-២០២៧) ថាមនុស្សម្នាក់ត្រូវបានគេប៉ាន់ប្រមាណជាមធ្យមត្រូវចំណាយថវិកា២៥ដុល្លារ ក្នុងថ្លៃព្យាបាលរៀងរាល់ឆ្នាំលើជំងឺមិនឆ្លង (MoH, 2018, p.7)។ រូបភាព២បង្ហាញថា មនុស្សម្នាក់បានចំណាយអស់២០%ជាមធ្យមនៃតម្លៃព្យាបាលសរុបលើជំងឺមិនឆ្លង ក្នុងរយៈពេល៤ឆ្នាំចុងក្រោយ (២០១៩-២០២២) ។ ខណៈដែលថវិកាប្រចាំឆ្នាំសម្រាប់ប្រយុទ្ធនឹងជំងឺមិនឆ្លងបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ នេះបង្ហាញថាមនុស្សម្នាក់ៗនឹងត្រូវចំណាយថវិកាផ្ទាល់ខ្លួនច្រើនទៅលើថ្លៃព្យាបាលជំងឺមិនឆ្លងនាពេលអនាគត។

---

[5] សេវាគាំទ្រការប្រយុទ្ធនឹងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀតសម្រាប់ថ្នាក់រាជធានី-ខេត្ត មិនត្រូវបានបែងចែកថវិកានោះទេ សម្រាប់ឆ្នាំ២០២២។

[6] World Bank. (2022). *GDP growth (annual %)—Cambodia | Data*. Retrieved from https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?end=2021&locations=KH&start=2021&view=bar

MoEF. (2022). ថវិកាសង្ខេប Archives. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ. Retrieved from https://mef.gov.kh/documents-category/publication/budget-in-brief/

*រូបភាព១៖ ថ្លៃចំណាយ និងបន្ទុកសេដ្ឋកិច្ចរបស់ជំងឺមិនឆ្លង*




ប្រភព៖ គណនាទិន្នន័យបានពី (World Bank, 2022; MoEF, 2022)

*រូបភាព២៖ ថ្លៃចំណាយ និងបន្ទុកហិរញ្ញវត្ថុរបស់ជំងឺមិនឆ្លង*




ប្រភព៖ គណនាទិន្នន័យបានពី (World Bank, 2022; MoEF, 2022)

## ៣. ផលប៉ះពាល់ពីជំងឺមិនឆ្លងលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាជន

អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ រកឃើញ១៦,៥% នៃសមាជិកគ្រួសារចំនួន ៤៤.៥៤៨នាក់ មានជំងឺក្នុងរយៈពេល ៣០ថ្ងៃចុងក្រោយមុនពេលការធ្វើអង្កេត[7] ហើយក្នុងនោះ ៣១% (២.២៧១នាក់) មានជំងឺមិនឆ្លង ។ ជំងឺមិនឆ្លងទាំងប្រាំដែលប៉ះពាល់ដល់មនុស្សច្រើនបំផុតរួមមាន ជំងឺសម្ពាធឈាមឡើងខ្ពស់ (៤០%) ជំងឺក្រពះ ពោះវៀន/រលាកក្រពះ (១៣%) ជំងឺបេះដូង (១០%) ជំងឺទឹកនោមផ្អែម (៩%) ជំងឺឈឺសន្លាក់ (៦%) និងជំងឺមិនឆ្លងផ្សេងទៀត (២១%)។

### *ផលប៉ះពាល់នៃជំងឺមិនឆ្លងលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម*

ការវិភាគបានបង្ហាញថា ១២.១% (ស្មើនឹងសមាជិកគ្រួសារ ២៧៥នាក់) នៃអ្នកជំងឺមិនឆ្លងសរុបទាំង ២.២៧១នាក់ បានផ្អាកសកម្មភាពចិញ្ចឹមជីវិតដោយសារតែជំងឺមិនឆ្លង។ ជាមធ្យម អ្នកជំងឺបានផ្អាកសកម្មភាពចិញ្ចឹមជីវិតចំនួន ១៣,៣៨ថ្ងៃ ក្នុង រយៈពេល៣០ថ្ងៃចុងក្រោយមុនពេលការធ្វើអង្កេតនៅឆ្នាំ២០១៩/២០២០។ ជំងឺដែលប៉ះពាល់ដល់សកម្មភាពចិញ្ចឹមជីវិតភាគច្រើនគឺ ជំងឺមហារីកមាត់ស្បូន បញ្ហាឈឺធ្មេញ ជំងឺទឹកនោមផ្អែម ជំងឺមហារីកសួត ជំងឺមហារីកថ្លើម កង្វះអាហារូបត្ថម្ភ និងជំងឺមិនឆ្លងផ្សេងទៀត។ លទ្ធផលវិភាគក៏បង្ហាញផងដែរថា ផលប៉ះពាល់នៃជំងឺមិនឆ្លងមានកាន់តែខ្លាំងទៅលើជីវភាពរស់នៅរបស់មនុស្សចាស់ ជាពិសេសអ្នកជំងឺដែលមានអាយុលើសពី៦៥ឆ្នាំ ប៉ុន្តែមិនពាក់ព័ន្ធនឹងលក្ខខណ្ឌយេនឌ័រ និងតំបន់រស់នៅរបស់ពួកគេឡើយ។

### *ការអនុវត្តព្យាបាលជំងឺមិនឆ្លង និងសុខុមាលភាពបច្ចុប្បន្ន*

ការអនុវត្តសុខុមាលភាពក្នុងចំណោមអ្នកជំងឺមិនឆ្លងទាំង ២.២៧១នាក់ មានតិចតួចនៅឡើយ ដោយមានតែ ៣៥%ប៉ុណ្ណោះ បានទៅមន្ទីរពេទ្យ ឬទទួលយកសេវាសុខភាពចំនួនជាមធ្យម ១,៥៩ដង ក្នុងរយៈពេល ៣០ថ្ងៃចុងក្រោយ។ ជាងនេះទៅទៀត អ្នកជំងឺមិនឆ្លងជាង ៧០% បានទៅគ្លីនិកឯកជន ឱសថស្ថានឯកជន មន្ទីរពេទ្យឯកជន និងមន្ទីរពេទ្យជាតិ បើធៀបនឹងកន្លែង និងសេវាសុខភាពផ្សេងទៀត។ លទ្ធផលនេះបានបង្ហាញពីការពឹងផ្អែកខ្ពស់នៃអ្នកជំងឺមិនឆ្លងលើមន្ទីរពេទ្យ និងសេវាកម្មឯកជន ជាជាងការទៅទទួលយកសេវាសុខភាពសាធារណៈ[8]។

### *បន្ទុកហិរញ្ញវត្ថុនៃជំងឺមិនឆ្លងទៅលើគ្រួសារអ្នកជំងឺ*

ការវិភាគបានបង្ហាញថា តម្លៃការព្យាបាលជំងឺមិនឆ្លងជាមធ្យមគឺ១២ដុល្លារ គិតក្នុងរយៈពេល៣០ថ្ងៃចុងក្រោយមុនពេលការធ្វើអង្កេត ។ លទ្ធផលវិភាគបានបង្ហាញថា មិនមានភាពខុសប្លែកគ្នានៃថ្លៃព្យាបាលជំងឺ

[7] CSES2019/20 ត្រូវបានធ្វើឡើងនៅក្នុងសំណាកភូមិតំណាងទូទាំងប្រទេសចំនួន១,០០៨ភូមិ ដែលបែងចែកជា១២ក្រុម ស្មើនឹង ៨៤ភូមិ សម្រាប់ការចុះប្រមូលទិន្នន័យក្នុងមួយខែម្តង។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងចាប់ពីខែកក្កដា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ2020 (NIS, 2020)

[8] សេវាសុខភាពសាធារណៈរួមមាន មន្ទីរពេទ្យខេត្ត ផ្ទះនិងបន្ទប់សម្រាកព្យាបាលរបស់គ្រូពេទ្យឬគិលានុបដ្ឋាកយិកា មន្ទីរពេទ្យបង្អែកស្រុក ហាងលក់ថ្នាំពេទ្យ គ្រូខ្មែរ សេវាសុខាភិបាលបរទេស និងសេវាសុខាភិបាលសាធារណៈបរទេសផ្សេងទៀត។

មិនឆ្លង គួរឱ្យកត់សម្គាល់ទៅលើគ្រួសារអ្នកជំងឺជាបុរសនិងស្ត្រីនោះទេ ប៉ុន្តែបន្ទុកថ្លៃព្យាបាលមានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងតំបន់រស់នៅរបស់អ្នកជំងឺ។ អ្នកជំងឺរស់នៅរាជធានីភ្នំពេញ និងតំបន់វាលទំនាបបានចំណាយខ្ពស់លើថ្លៃព្យាបាលជំងឺមិនឆ្លងច្រើនជាងអ្នកជំងឺរស់នៅតំបន់ភ្នំចំនួន (០.៣៤២៤ ដុល្លារ) និង (០.២៤២៨ ដុល្លារ) រៀង។

### *ឥទ្ធិពលនៃការអនុវត្តសុខុមាលភាព និងសេដ្ឋកិច្ចសង្គមទៅលើថ្លៃព្យាបាលជំងឺមិនឆ្លង*

ការវិភាគ Multiple regression បានបង្ហាញពីសារៈសំខាន់នៃការអនុវត្តសុខុមាលភាព ជាពិសេសលើភាពញឹកញាប់នៃការស្វែងរកការថែទាំសុខភាព ដែលនឹងជួយកាត់បន្ថយថ្លៃព្យាបាលជំងឺមិនឆ្លង។ ការអនុវត្តការពិគ្រោះយោបល់ញឹកញាប់ជាមួយ អ្នកផ្តល់សេវាសុខភាព និងទទួលយកសេវាសុខភាព ធ្វើឱ្យតម្លៃព្យាបាលជំងឺមិនឆ្លងនឹងថយចុះ។ ករណីនេះ អនុវត្តចំពោះការការពារ និងការព្យាបាលជាមុន មុនពេលមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបង្កឡើងដោយជំងឺមិនឆ្លង។ ចុងក្រោយ ការវិភាគ Multiple regression បានបង្ហាញថា អាយុ យេនឌ័រ និងចំនួនយប់នៃការសម្រាកព្យាបាលនៅមន្ទីរពេទ្យ មិនមានឥទ្ធិពលគួរឱ្យកត់សម្គាល់ដល់តម្លៃនៃការព្យាបាលជំងឺមិនឆ្លងនោះទេ។

### *យុទ្ធសាស្ត្រទប់ទល់ថ្លៃព្យាបាលជំងឺមិនឆ្លងក្នុងគ្រួសារ*

យុទ្ធសាស្ត្រទប់ទល់ថ្លៃព្យាបាលជំងឺមិនឆ្លងក្នុងគ្រួសារ មានចំនួនប្រាំមួយត្រូវបានប្រើ៖ ប្រាក់ចំណូលគ្រួសារ ការសន្សំ ការខ្ចីប្រាក់ ការលក់ទ្រព្យសម្បត្តិ ការលក់ផលិតកម្មគ្រួសារជាមុន និងប្រភពផ្សេងទៀត។ ក្នុងនោះគ្រួសារដែលមានជំងឺមិនឆ្លង ច្រើនជាង ៧០% បានប្រើប្រាស់ប្រាក់ចំណូលគ្រួសារ ដើម្បីទប់ទល់នឹងការចំណាយលើការព្យាបាលជំងឺមិនឆ្លង ហើយមានតែ ២៥% ប៉ុណ្ណោះ ដែលបានប្រើប្រាស់ប្រាក់សន្សំរបស់ពួកគេ។ លើសពីនេះ មានតិចជាង ១០% នៃអ្នកជំងឺមិនឆ្លងមានយុទ្ធសាស្ត្រដោះស្រាយបន្ទុកហិរញ្ញវត្ថុទីពីរ (ប្រើយុទ្ធសាស្ត្របំរុង)។ លទ្ធផលនេះបានបង្ហាញថា មានតែអ្នកជំងឺ មួយភាគបីប៉ុណ្ណោះ ដែលបានរៀបចំផែនការថវិកាសម្រាប់ជំងឺមិនឆ្លងរបស់ពួកគេ ខណៈដែលភាគច្រើនមិនបានរៀបចំថវិកា ឬយុទ្ធសាស្ត្រដោះស្រាយសម្រាប់ជំងឺទាំងនោះទេ។ ក្នុងករណីជំងឺមិនឆ្លងកើតឡើងធ្ងន់ធ្ងរលើគ្រួសារ នោះទំនោរក្នុងការខ្ចីប្រាក់ និងចងការប្រាក់ពីអ្នកដទៃនឹងកើនឡើងយ៉ាងខ្លាំង។

### *ការកំណត់ធនធានដែលមានសក្តានុពលដើម្បីដោះស្រាយហានិភ័យនៃជំងឺមិនឆ្លង*

ធនធានដែលមានសក្តានុពលចំនួនប្រាំបី សម្រាប់ការប្រយុទ្ធនឹងជំងឺមិនឆ្លងរួមមាន៖ បង្កើនកញ្ចប់ថវិកាក្រសួងសុខាភិបាល រួមបញ្ចូលសេវាជំងឺមិនឆ្លងទៅក្នុងកម្មវិធីបង្ការនិងថែទាំព្យាបាលជំងឺអេដស៍ យកពន្ធលើផលិផលដែលប៉ះពាល់សុខភាព បែងចែកកញ្ចប់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បង្កើតមូលនិធិសុខាភិបាលដើម្បីកៀគរថវិកាថ្នាក់ក្រោមជាតិ បង្កើនការវិនិយោគរបស់វិ-ស័យឯកជននៅក្នុងដំណោះស្រាយបញ្ហាជំងឺមិនឆ្លង បង្កើតការវិនិយោគថ្មីលើការបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លង និងចូលរួមការគាំទ្ររួមគ្នាដោយការពង្រីក និងធ្វើពិពិធកម្មភាគីពាក់ព័ន្ធជំងឺមិនឆ្លងនៅទូទាំងវិស័យទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដើម្បីទទួលបានធនធានទាំងនេះ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គួរធ្វើការរួមគ្នា។ ជាងនេះទៅទៀត ទំនាក់ទំនង និងការសម្របសម្រួល រវាងភាគីពាក់ព័ន្ធសំខាន់ៗ និងវិស័យឯកជន ចាំបាច់

ត្រូវពង្រឹងតាមរយៈភាពជាដៃគូ-វាងវិស័យសាធារណៈ និងឯកជននៅថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីឱ្យការបែងចែកធនធានបានសមស្រប។

## ការពិភាក្សាលើលទ្ធផលរកឃើញ

ជំងឺមិនឆ្លងបានបណ្តាលឱ្យមានបន្ទុកសេដ្ឋកិច្ច៦,៦% ដែលក្នុងនោះថវិកាជាង ៥,៩៧ពាន់ពាន់លានរៀល ត្រូវបានបាត់បង់ជារៀងរាល់ឆ្នាំ តាមរយៈការចំណាយដោយប្រយោល (អវត្តមានការងារ ការថយចុះសមត្ថភាពធ្វើការ និងការស្លាប់មុនអាយុ៧០ឆ្នាំ)។ ប៉ុន្តែ រដ្ឋាភិបាលនៅធ្វើការចំណាយថវិកាតិចតួចនៅឡើងលើជំងឺមិនឆ្លង បើធៀបនឹងថវិកាសុខភាពសាធារណៈរបស់ក្រសួងសុខាភិបាល។ ជាក់ស្តែង ថវិកាចំណាយនៃជំងឺមិនឆ្លងមានមានត្រឹមតែ ០,១២% ឬស្មើនឹង ១.៥៤៣,៣០លានរៀលប៉ុណ្ណោះ បើធៀបនឹងផែនការថវិកាសុខភាពសាធារណៈសរុបដែលមានចំនួន ១.៣៤១.៣៧៧,០០លានរៀលក្នុងឆ្នាំ២០២២ ដែលត្រូវបានបែងចែកទៅកម្មវិធីទី១ ទី២ និងទី៤។ តាមរយៈការវិភាគនេះ វាបានបង្ហាញថារដ្ឋាភិបាលកម្ពុជានៅធ្វើការចំណាយតិចតួចសម្រាប់ការងារការគ្រប់គ្រង ការបង្ការ និងព្យាបាលជំងឺមិនឆ្លង ទោះបីជាជំងឺនេះបណ្តាលឱ្យមានបន្ទុកសេដ្ឋកិច្ច និងសុខភាពសាធារណៈក៏ដោយ (Mogojwe, 2021)។

ថវិកាសម្រាប់ជំងឺរ៉ាំរ៉ៃមានត្រឹមតែ ០,០០៤% បើធៀបនឹងថវិកាសុខភាពសាធារណៈសរុបក្នុងឆ្នាំ ២០២២។ ដូចដែលបានកត់សម្គាល់ឃើញថា ក្នុងចំណោមអ្នកជំងឺមិនឆ្លងចំនួន ២.២៧១នាក់ មានជំងឺសម្ពាធឈាមឡើងខ្ពស់(៤០%) ជំងឺក្រពះពោះវៀន/រលាកក្រពះ (១៣%) ជំងឺបេះដូង (១០%) ជំងឺទឹកនោមផ្អែម (៩%) ជំងឺឈឺសន្លាក់ (៦%) និងជំងឺមិនឆ្លងផ្សេងៗទៀត (២១%)។ តាមរយៈលទ្ធផលទាំងនេះ ការសិក្សាស្នើពិនិត្យមើលឡើងវិញនូវការបែងចែកថវិកាសម្រាប់ជំងឺរ៉ាំរ៉ៃ។

ទន្ទឹមនឹងនេះ ជំងឺមិនឆ្លងបានប៉ះពាល់ដល់សុខភាពអ្នកជំងឺ ជាពិសេសចំពោះមនុស្សចាស់ ប៉ុន្តែការអនុវត្តសុខុមាលភាពនៅមានកម្រិតតិចតួចនៅឡើយ។ ជាក់ស្តែង ផ្អែកទៅលើអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៩/២០ មានតែអ្នកជំងឺ ៣៥% ប៉ុណ្ណោះដែលបានទៅមន្ទីរពេទ្យ ឬទទួលយកសេវាសុខភាពក្នុងរយៈពេល ៣០ថ្ងៃចុងក្រោយមុនពេលការធ្វើអង្កេត។ ការអនុវត្តសុខុមាលភាពមានកម្រិតតិចតួចបែបនេះ នឹងក្លាយជាបញ្ហាប្រឈមមួយសម្រាប់ការព្យាបាលជំងឺមិនឆ្លង ហើយត្រូវចំណាយច្រើ-ន។ ដើម្បីឱ្យការព្យាបាលជំងឺមិនឆ្លងកាន់តែប្រសើរឡើង អង្គការសុខភាពពិភពលោក បានណែនាំឱ្យអ្នកជំងឺមកព្យាបាលឱ្យបានញឹកញាប់ និងទាន់ពេលវេលា ជាពិសេសចំពោះអ្នកជំងឺមានវ័យចំណាស់ (Akkazieva et al., 2014)។ ជាងនេះទៅទៀត ការវិភាគក៏បានបង្ហាញថា ការទទួលបានការព្យាបាលញឹកញាប់ និងទាន់ពេលវេលា នឹងជួយកាត់បន្ថយការចំណាយលើការព្យាបា-ល។ ដូច្នេះការលើកកម្ពស់ការយល់ដឹងអំពីសុខុមាលភាពសម្រាប់ជំងឺមិនឆ្លង នឹងជួយទាំងលទ្ធផលនៃការព្យាបាល និងកាត់បន្ថយការចំណាយផងដែរ។

ជាចុងក្រោយ មានការព្រួយបារម្ភអំពីបំណុលគ្រួសារ ដោយសារការចំណាយពីហោប៉ៅច្រើនទៅលើការព្យាបាលជំងឺមិនឆ្លង។ ការសិក្សាបានរកឃើញថា ជាង៧០% នៃគ្រួសារដែលមានជំងឺមិនឆ្លង បានប្រើប្រាស់ប្រាក់ចំណូលគ្រួសាររបស់ពួកគេ ដើម្បីទប់ទល់នឹងការចំណាយលើការព្យាបាល ហើយមានតែ ២៥% ប៉ុណ្ណោះដែលប្រើប្រាស់ប្រាក់សន្សំរបស់ពួកគេ។ លទ្ធផលនេះបានបង្ហាញថា មានតែអ្នកជំងឺមួយភាគបី ប៉ុណ្ណោះដែលបានរៀបចំផែនការថវិកាសម្រាប់ជំងឺមិនឆ្លងរបស់ពួកគេ

ខណៈដែលភាគច្រើនមិនបានរៀបចំថវិកា ឬយុទ្ធសាស្ត្រដោះស្រាយសម្រាប់ជំងឺទាំងនោះទេ។ ក្នុងករណីជំងឺមិនឆ្លងកើតឡើងធ្ងន់ធ្ងរលើគ្រួសារ នោះទំនោរក្នុងការខ្ចីប្រាក់ និងចងការប្រាក់ពីអ្នកដទៃនឹងកើនឡើងយ៉ាងខ្លាំង។

ការគូសវាសធនធានសម្រាប់ជំងឺមិនឆ្លងនៅក្នុងការសិក្សានេះបានស្របជាមួយនឹងឯកសារស្តីពី ការបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លង៖ ការណែនាំសម្រាប់ករណីវិនិយោគ (WHO & UNDP, 2019) ដែលបានពិនិត្យមើលលើការយកពន្ធពីផលិតផលដែលបង្កគ្រោះថ្នាក់ដល់សុខភាព និងការចំណាយលើវិស័យសាធារណៈ។ លើសពីនេះ ការសិក្សាក៏បានរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងអំពីការចំណាយពិតប្រាកដនៃជំងឺមិនឆ្លង និងអត្ថប្រយោជន៍នៃការអនុវត្តសុខុមាលភាពដែល បានណែនាំ (Akkazieva et al., 2014; UNDP, 2020)។ ការរកឃើញនេះ ក៏រួមចំណែកដល់ផែនការសកម្មភាពពហុវិស័យជាតិសម្រាប់ការបង្ការ និងការប្រយុទ្ធនឹងជំងឺមិនឆ្លង (២០១៨-២០២៧) លើការគូសវាស និងការបែងចែកធនធាន (MoH, 2018)។ ជាចុងក្រោយការសិក្សាបានស្នើឱ្យពង្រឹងការធ្វើផែនការនិងការសម្របសម្រួលថ្នាក់ជាតិរវាងភាគីពាក់ព័ន្ធសំខាន់ៗលើការងារបង្ការ និងគ្រប់គ្រប់ជំងឺមិនឆ្លង តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន (UNDP, 2020)។

## សេចក្តីសន្និដ្ឋាន

ការសិក្សាបានរកឃើញថា ថវិកាចំណាយសម្រាប់ជំងឺមិនឆ្លងមានត្រឹមតែ ០,១២% ឬស្មើនឹង ១.៥៤៣,៣០លានរៀលប៉ុណ្ណោះ បើប្រៀបធៀបនឹងផែនការថវិកាសុខភាពសាធារណៈសរុបដែលមានចំនួន ១.៣៤១.៣៧៧,០០លានរៀលក្នុងឆ្នាំ២០២២។ ជាងនេះទៅទៀត សុខភាពផ្លូវចិត្ត និងការញៀនថ្នាំ សុខភាពមាត់ធ្មេញ និងបញ្ហាសុខភាពសាធារណៈផ្សេងៗទៀត បានប្រើអស់ថវិកាស្ទើរទាំងស្រុងនៃថវិកាសម្រាប់កម្មវិធីប្រយុទ្ធនឹងជំងឺមិនឆ្លង ខណៈជំងឺរ៉ាំរ៉ៃ ដែលជាជំងឺប៉ះពាល់ខ្លាំងដល់ប្រជាជន មានកញ្ចប់ថវិកាត្រឹមតែ ០,០០៤% បើធៀបនឹងថវិកាសុខភាពសាធារណៈសរុបក្នុងឆ្នាំ២០២២។

បន្ថែមពីនេះ ជំងឺដែលប៉ះពាល់ដល់សកម្មភាពចិញ្ចឹមជីវិតភាគច្រើនគឺ ជំងឺមហារីកមាត់ស្បូន បញ្ហាឈឺធ្មេញ ជំងឺទឹកនោមផ្អែម ជំងឺមហារីកសួត ជំងឺមហារីកថ្លើម កង្វះអាហារូបត្ថម្ភ និងជំងឺមិនឆ្លងផ្សេងទៀត។ ជំងឺមិនឆ្លងទាំងនេះប៉ះពាល់ដល់ជីវភាពរស់នៅនិងសុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេសចំពោះមនុស្សចាស់ ប៉ុន្តែការអនុវត្តសុខុមាលភាពរបស់ប្រជាពលរដ្ឋក៏នៅមានកម្រិតនៅឡើយ។ ប្រជាពលរដ្ឋកម្ពុជាមិនសូវទៅទទួលយកសេវាព្យាបាលជាប្រចាំ ដែលបញ្ហានេះនឹងធ្វើឱ្យពួកគាត់ប្រឈមការចំណាយលើការព្យាបាលកាន់តែមានតម្លៃខ្ពស់ផងដែរ។ លើសពីនេះ មានការព្រួយបារម្ភអំពីបំណុលគ្រួសារ ដោយសារការចំណាយពីហោប៉ៅច្រើនលើការព្យាបាលជំងឺមិនឆ្លង។ ការសិក្សាបានរកឃើញថា មានតែអ្នកជំងឺ មួយភាគបីប៉ុណ្ណោះដែលបានរៀបចំផែនការថវិកាសម្រាប់ជំងឺមិនឆ្លងរបស់ពួកគេ ខណៈដែលភាគច្រើនមិនបានរៀបចំថវិកា ឬយុទ្ធសាស្ត្រដោះស្រាយ សម្រាប់ជំងឺទាំងនោះទេ។ ក្នុងករណីជំងឺមិនឆ្លងកើតឡើងធ្ងន់ធ្ងរលើគ្រួសារ នោះទំនោរក្នុងការខ្ចីប្រាក់ និងចងការប្រាក់ពីអ្នកដទៃនឹងកើនឡើងយ៉ាងខ្លាំង។

# ឯកសារយោង


Akkazieva, B., Tello, J., Smith, B., Jakab, M., Krasovsky, K., Sautenkova, N., Yuldasheva, L., & Shoismatuloeva, M. (2014). *Better noncommunicable disease outcomes: Challenges and opportunities for health systems. TAJIKISTAN country assessment*.

MoEF. (2022). ថវិកាសង្ខេប Archives. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. Retrieved from https://mef.gov.kh/documents-category/publication/budget-in-brief/

Mogojwe, H. (2021, December 17). *Integrating early non-communicable disease screening and counseling with COVID-19 vaccinations in Cambodia*. Clinton Health Access Initiative. Retrieved from https://www . clintonhealthaccess.org/blog/integrating-early-non-communicable-disease-screening-and-counseling-with-covid-19-vaccinations-in-cambodia/

MoH. (2018). *Policies and Sector Strategic Plans – Ministry of Health* [National Multisectoral Action Plan for the Prevention and Control of Noncommunicable Diseases 2018-2027]. Retrieved from http://moh.gov.kh

NIS. (2020). *Cambodia Socio-Economic Survey 2019-20*. Retrieved from https://www.nis.gov.kh/index.php/en/14-cses/86-cambodia-socia-ecomonic-survey-2019-20

UNDP. (2020). *Prevention and control of noncommunicable diseases in Cambodia | United Nations Development Programme*. Retrieved from https://www.undp.org/ cambodia/publications/prevention-and-control-noncommunicable-diseases-cambodia

WHO. (2022). *Global Health Expenditure Database*. World Health Organization. Retrieved from https://apps.who.int/nha/ database/country_profile/Index/en

WHO, & UNDP. (2019). *Non-communicable disease prevention and control: A guidance note for investment cases* (WHO/NMH/NMA/19.95). World Health Organization. Retrieved from https://apps.who.int/iris/handle /10665/311180